**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៣២៤ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ
# នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ



៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
kat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- យោងអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ៦០អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ ២.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំឲ្យមានគណៈកម្មាធិការលទ្ធកម្មរៀងៗខ្លួន ដើម្បីធានាឲ្យការគ្រប់គ្រង ការដឹកនាំ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និង ការជួលសេវាទីប្រឹក្សាប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលា។

**ប្រការ ៣.-**

គណៈកម្មាធិការលទ្ធកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

**ប្រការ ៤.-**

អង្គភាពលទ្ធកម្មរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក សាលាខណ្ឌ។

**ប្រការ ៥.-**

រដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានីត្រូវរាយការណ៍ជូនរដ្ឋបាលរាជធានីអំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

រដ្ឋបាលសង្កាត់ចំណុះក្រុង ត្រូវរាយការណ៍ជូនរដ្ឋបាលក្រុងអំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

## ជំពូកទី ២
## គណៈកម្មាធិការលទ្ធកម្ម

**ប្រការ ៦.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - អភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងរាជធានី ខេត្ត ០១រូប | អនុប្រធាន |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - សមាជិកក្រុមប្រឹក្សារាជធានី ខេត្តយ៉ាងច្រើន០៣រូប | សមាជិក |
| - នាយករដ្ឋបាលនៃសាលារាជធានី ខេត្ត | សមាជិក |
| - នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត | លេខាធិការ |

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មដែលជាអភិបាលរង ត្រូវស្នើដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

សមាសភាពនៃគណៈកម្មាធិការលទ្ធកម្មរាជធានី ខេត្ត ដែលជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវជ្រើសរើសដោយក្រុមប្រឹក្សារាជធានី ខេត្ត។

**ប្រការ ៧.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានសមាសភាពដូចខាងក្រោម៖

- អភិបាលក្រុង ស្រុក ខណ្ឌ — ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ ០១រូប — អនុប្រធាន
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយ៉ាងច្រើន០៣រូប — សមាជិក
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ — លេខាធិការ

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវស្មើដោយអភិបាលក្រុង ស្រុក ខណ្ឌ។

សមាសភាពនៃគណៈកម្មាធិការលទ្ធកម្មក្រុង ស្រុក ខណ្ឌ ដែលជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវជ្រើសរើសដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

**ប្រការ ៨.-**

ក្នុងដំណើរការកិច្ចលទ្ធកម្មនីមួយៗ ប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវតែងតាំងសមាជិកចំពោះកិច្ចមួយចំនួន ដែលជាមន្ត្រីមានសមត្ថភាពគាំទ្របច្ចេកទេសមកពីអង្គភាព ស្ថាប័នរបស់រដ្ឋ ឬ ជួលពីខាងក្រៅដោយប្រើប្រាស់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអាចអញ្ជើញមន្ត្រីជំនាញក្នុងរដ្ឋបាលរបស់ខ្លួន ឬ ពីអង្គភាព ស្ថាប័នរដ្ឋផ្សេងៗទៀត ដើម្បីជួយផ្តល់យោបល់។

សមាជិកចំពោះកិច្ចនៃគណៈកម្មាធិការលទ្ធកម្មត្រូវរំសាយដោយស្វ័យប្រវត្តិនៅពេលកិច្ចលទ្ធកម្មនោះត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ ៩.-**

សមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការលទ្ធកម្ម។

**ប្រការ ១០.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវធ្វើសេចក្តីសម្រេចដោយសម្លេងភាគច្រើន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានគណៈកម្មាធិការលទ្ធកម្មមានឧត្តមានុភាព។

**ប្រការ ១១.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃ កំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន។ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃឡើងវិញលើលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខមុនការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះនិងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មលើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ១២.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលរៀបចំដោយអង្គភាពលទ្ធកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងអនុម័ត។
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃ កំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ត្រួតពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃឡើងវិញលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន ។

## ជំពូកទី ៣

## អង្គភាពលទ្ធកម្ម

**ប្រការ ១៣.-**

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានរចនាសម្ព័ន្ធស្ថិតក្រោមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្ទាល់ និងជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាល

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ប្រធានអង្គភាពលទ្ធកម្មជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម ។

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវដឹកនាំដោយប្រធានមួយ(០១) រូប និងមានអនុប្រធានយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ដែលមិនត្រូវមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួនឡើយ។

**ប្រការ ១៤.-**

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តមានកម្រិតស្មើនឹងទីចាត់ការសាលារាជធានី ខេត្ត។ ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តមានឋានៈស្មើនាយក និងនាយករងទីចាត់ការសាលារាជធានី ខេត្ត ។

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានកម្រិតស្មើនឹងការិយាល័យសាលាក្រុង ស្រុក ខណ្ឌ។ ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានឋានៈស្មើប្រធាន និងអនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ។

**ប្រការ ១៥.-**

ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានតែងតាំង ឬផ្លាស់ប្តូរដោយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌតាមសំណើរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើលក្ខណៈសម្បត្តិដែលត្រូវតែងតាំង តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ លក្ខខណ្ឌនៃការតែងតាំងប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រធានអង្គភាពលទ្ធកម្មត្រូវមានលក្ខណៈសម្បត្តិបន្ថែមដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុយ៉ាងតិច ៣ឆ្នាំ និង
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនប័ត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ១៦.-**

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ

- លក់ ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារ ឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើដេញថ្លៃ
- ចាត់ចែងរៀបចំទីកន្លែងសម្រាប់បើកសំណើដេញថ្លៃ
- រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយមានការដឹកនាំត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- ផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ធ្វើសេចក្តីព្រាងកិច្ចសន្យាឱ្យសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យាដែលបានកំណត់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

**ប្រការ ១៧.-**

ត្រូវបានផ្ទេរការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្ត ដែលកំណត់ក្នុងប្រកាសលេខ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ និងប្រកាសលេខ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ដើម្បីបង្កើតអង្គភាពលទ្ធកម្មមួយដោយឡែកចំណុះរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ខេត្តត្រូវផ្ទេរប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិក ឧបករណ៍ សម្ភារៈមធ្យោបាយ និងការងារពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មពីការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្តទៅឲ្យអង្គភាពលទ្ធកម្មនៃសាលារាជធានី ខេត្តដែលបង្កើតថ្មីតាមស្មារតីប្រកាសនេះ។

រដ្ឋបាលក្រុង ស្រុកត្រូវផ្ទេរមន្ត្រី បុគ្គលិក ឧបករណ៍ សម្ភារៈ មធ្យោបាយ និងការងារពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មពីការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុកទៅឲ្យអង្គភាពលទ្ធកម្មសាលាក្រុង ស្រុកដែលបង្កើតថ្មីតាមស្មារតីប្រកាសនេះ។

ក្នុងករណីតែងតាំងប្រធានអង្គភាពលទ្ធកម្មដែលត្រូវជ្រើសរើសបេក្ខភាពផ្សេងពីប្រធានការិយាល័យលទ្ធកម្មបច្ចុប្បន្ន និងក្នុងករណីមានការស្នើសុំផ្លាស់ប្តូរប្រធានអង្គភាពលទ្ធកម្មនាពេលខាងមុខ បេក្ខភាពដែលស្នើសុំតែងតាំង ឬជំនួសត្រូវមានលក្ខណៈសម្បត្តិដូចមានចែងក្នុងប្រការ១៥នៃប្រកាសនេះ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**ប្រការ ១៨.-**

ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុត្រូវធ្វើ ប្រតិភូកម្មអំណាចឲ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីៈ

- ពិនិត្យនិងអនុម័តផែនការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង
- ពិនិត្យនិងសម្រេចលើកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ប្រការ ១៩.-**

នៅពេលមិនទាន់មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលរាជធានី ខេត្តត្រូវលើកសំណើសុំតែងតាំង ឬផ្លាស់ប្តូរប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យសម្រេចតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។ អភិបាលរាជធានី អភិបាលខេត្ត យោងតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌដែលមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យ សម្រេចលើការតែងតាំង ឬផ្លាស់ប្តូរប្រធាន និងអនុប្រធាន អង្គភាព លទ្ធកម្មសាលាក្រុង ស្រុក ខណ្ឌស្របតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។

**ប្រការ ២០.-**

ផ្អែកតាមការកំណត់នៃប្រការ១៤ ខាងលើ ប្រាក់បំណាច់មុខងារប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមមាត្រា១៤៥ នៃអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ និងមាត្រា២០៧ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការ ងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល ស្រុក។

**ប្រការ ២១.-**

ផ្អែកតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាមទារឲ្យមានការរៀបចំនូវយន្តការ នីតិវិធី ការតែងតាំងមន្ត្រី និងការបណ្តុះបណ្តាលកសាងសមត្ថភាពជាមុន។ ការរៀបចំនូវកិច្ចដំណើរការទាំងនេះត្រូវអនុវត្តភ្លាមបន្ទាប់ពីប្រកាសនេះចូលជាធរមាន ដើម្បីឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានលទ្ធភាពអនុវត្តនូវកិច្ចលទ្ធកម្មសាធារណៈរបស់ខ្លួន ក្នុងពេលវេលាសមស្របណាមួយក្នុងឆ្នាំ២០១៣។

ក្នុងពេលដែលកិច្ចដំណើរការខាងលើនេះពុំទាន់បានរៀបចំចប់សព្វគ្រប់ កិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមយន្តការ និងនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២៣.-**

ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាសង្កាត់ អង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

<u>ចម្លងជូន:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានគ.ជ.អ.ប
- ដូចប្រការ ២៣
- ឯកសារ-កាលប្បវត្តិ